World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៧០ សប្តាហ៍ទី៨៣

០១ ខែវិច្ឆិកា ឆ្នាំ២០២១

របាយការណ៍គិតត្រឹមថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង១០:០០នាទីព្រឹក

## ស្ថានការណ៍សង្ខេប

### សម្រង់សង្ខេបនៃរបាយការណ៍អំពីស្ថានភាពជំងឺកូវីដ-១៩ ពេលបច្ចុប្បន្ន

- ករណីវិជ្ជមានវីរុសកូវីដ-១៩ សរុបចំនួន ៧២៥ និងករណីស្លាប់ចំនួន ៩៩ ត្រូវបានរាយការណ៍នៅក្នុងរយ:ពេល៧ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោម ៧២៥ ករណីនោះ មានករណីនាំចូលចំនួន ១០៥ (១៤,៥ ភាគរយ) និងករណីឆ្លងក្នុងស្រុកចំនួន ៦២០ ឬស្មើនឹង ៨៥,៥ ភាគរយ។
- គិតត្រឹមថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១០ ម៉ោងសកល ករណីសរុបទាំងអស់ចំនួន ១១៨.៦១៣ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ២.៧៩៤ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះ ១១៤.៩០២ ករណី បានជាសះស្បើយ។ ករណីនាំចូលពីក្រៅប្រទេសសរុបមានចំនួន ១៩.៦៤១ ឬស្មើនឹង ១៦.៦ ភាគរយនៃករណីជំងឺកូវីដ-១៩ ទាំងអស់។
- ចាប់តាំងពីខែមករា ឆ្នាំ២០២០ មក បុគ្គលសរុបចំនួន ១.៧០០.៧៦៣នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Real-Time Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥,២ ភាគរយ។ ជាសរុប គិតត្រឹមថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២១ ចំនួនតេស្ត ២.២៨៦.៩៦១ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍។
- កាលពីថ្ងៃទី ២៦ ខែតុលាឆ្នាំ២០២១ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណ:កម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានសម្រេចលើកលែងកាតព្វកិច្ចធ្វើចត្តាឡីស័កចំពោះអ្នកជំងឺកូវីដ-១៩ដែលបានបញ្ចប់ការព្យាបាលនៅតាមមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ និងអ្នកជំងឺកូវីដ-១៩សម្រាកថៃទាំ និងព្យាបាលនៅតាមផ្ទះ។
- កាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០២១ ក្រសួងសុខាភិបាល ផ្តល់ជូនវិញ្ញាបនបត្រអនុញ្ញាតប្រើប្រាស់ក្នុងលក្ខខណ្ឌបន្ទាន់សម្រាប់វ៉ាក់សាំង Sputnik-V, CoviVac, Sputnik-Light, EpiVacCorona។

## ព្រឹត្តិការណ៍ដែលនឹងកើតមាន និងវិធានការអាទិភាព

**ការតាមដានជំងឺ**

- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក កំពុងធ្វើការវិភាគស្ថានភាពជាប្រចាំ ដើម្បីស្វែងយល់អំពីប្រសិទ្ធភាពនៃអន្តរាគមន៍នានា ដោយប្រើប្រព័ន្ធតាមដានជំងឺផ្អែកលើព័ត៌មានច្រើនប្រភពមកពីថ្នាក់ក្រោមជាតិ។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលក្នុងការរៀបចំសេចក្តីណែនាំស្តីពីការតាមដានការអនុវត្ត និងអនុលោមតាមវិធានការសុខភាពសាធារណ:មិនមែនឱសថជាផ្នែកមួយនៃការតាមដាន និងវាស់វែងការអនុវត្តវិធានការសុខភាពសាធារណ:មិនមែនឱសថនៅថ្នាក់ក្រោមជាតិ។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ការត្រួតពិនិត្យមើលលើអត្រានៃការប្រើប្រាស់គ្រែសម្រាប់ព្យាបាលជំងឺធ្ងន់ នៅកម្រិតថ្នាក់ក្រោមជាតិ ហើយនិងពង្រឹងប្រព័ន្ធតាមដានជំងឺដើម្បីពិនិត្យតាមដានមើលករណីធ្ងន់ធ្ងរ។
- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួងសុខាភិបាលនៅក្នុងការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តតាមដានជំងឺកូវីដ-១៩ ដើម្បីរៀបចំទុកជាមុនសម្រាប់សេណារីយ៉ូនៃការរាតត្បាតជំងឺកូវីដ-១៩។
- ក្រសួងសុខាភិបាលដោយទទួលបានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការដៃគូ កំពុងតែស៊ើបអង្កេតករណីស្លាប់នៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញ ដើម្បីបង្កើនការយល់ដឹងពីមូលហេតុនៃការស្លាប់ ការទទួលបានការថែទាំ និងការចម្លងជំងឺកូវីដ-១៩នៅក្នុងសហគមន៍។
- ក្រសួងសុខាភិបាល រួមជាមួយនឹងអង្គការសុខភាពពិភពលោក កំពុងតែពង្រឹងសមត្ថភាពនៃប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ សមត្ថភាពក្រុមឆ្លើយតបបន្ទាន់នៅក្នុងខេត្តចំនួន៥ ដើម្បីស៊ើបអង្កេត និងប្រើប្រាស់របៀបតាមដានជំងឺដោយប្រើព័ត៌មានច្រើនប្រភពក្នុងការវាយតម្លៃស្ថានភាពអេពីដេមីសាស្រ្ត និងអនុវត្តការឆ្លើយតបចំគោលដៅ ក៏ដូចជាពង្រឹងការធ្វើចត្តាឡីស័កប្រកបដោយសុវត្ថិភាព។

**មន្ទីរពិសោធន៍**

- វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អង្គការសុខភាពពិភពលោក និងអង្គការដៃគូផ្សេងទៀត កំពុងផ្តល់ជំនួយផ្នែកបច្ចេកទេស និងផ្នែកសម្របសម្រួលដល់វិទ្យាស្ថានជាតិសុខភាពសាធារណ: នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល និងមន្ទីរពិសោធន៍វីរុសកូវីដ-១៩ ដើម្បីធានាឲ្យមាននិរន្តរភាពនៃសមត្ថភាពធ្វើតេស្ត។
- ផែនការពង្រីកមន្ទីរពិសោធន៍ កំពុងបន្តនៅមន្ទីរពិសោធន៍ដែលកំពុងដំណើរការស្រាប់ចំនួន១៨ ហើយការពង្រីមន្ទីរពិសោធន៍ចំនួន ៣ ផ្សេងទៀតនឹងត្រូវធ្វើនៅក្នុងខែវិច្ឆិកា។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ○ វិទ្យាស្ថានជាតិសុខភាពសាធារណៈ បាននិងកំពុងធ្វើការជាមួយនឹងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អង្គការសុខភាពពិភពលោក និងដៃគូ រៀបចំ និងគាំទ្រការអនុវត្តកម្មវិធីគ្រប់គ្រងសារពើភ័ណ្ឌ និងកម្មវិធីធានាគុណភាព (External Quality Assurance) ដើម្បីធានាគុណភាពតេស្តនៅមន្ទីរពិសោធន៍រកវីរុសកូវីដ-១៩ទាំងអស់។
- ○ អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងសម្របសម្រួលដល់វិទ្យាស្ថានសុខភាពសាធារណៈនៅក្នុងការរៀបចំការបណ្តុះបណ្តាលតាមអនឡាញស្តីពីការរៀបចំកម្មវិធីធានាគុណភាព (External Quality Assurance) ដើម្បីបង្កើតកម្មវិធីជាតិធានាគុណភាពតេស្តនៅមន្ទីរពិសោធន៍រកវីរុសកូវីដ-១៩។
- ○ អង្គការសុខភាពពិភពលោកប្រចាំប្រទេសកម្ពុជា ដោយមានការជួយគាំទ្រពីអង្គការសុខភាពពិភពលោកថ្នាក់តំបន់ប៉ាស៊ីហ្វិកខាងលិច កំពុងតែផ្តល់ការគាំទ្រដល់វិទ្យាស្ថានជាតិសុខភាពសាធារណៈនៅក្នុងការពង្រឹងសមត្ថភាពវិភាគលំដាប់ហ្សែនទាំងមូល (whole genome sequencing)ដើម្បីកំណត់រកវីរុសកូវីដ-១៩បំប្លែងថ្មី និងតាមដានរកមើលវីរុសបំប្លែងថ្មីដែលគួរឱ្យបារម្ភក៏ដូចជាវីរុសបំប្លែងថ្មីដែលគួរឱ្យចាប់អារម្មណ៍តាមរយៈការធ្វើលទ្ធកម្មសម្ភារមន្ទីរពិសោធន៍។
- ○ អង្គការសុខភាពពិភពលោក កំពុងផ្តល់ប្រឹក្សាបច្ចេកទេស និងយោបល់ដល់ក្រសួងសុខាភិបាលអំពីយុទ្ធសាស្ត្រយកសំណាកសម្រាប់ការតាមដានលំដាប់ហ្សែននៃវីរុសកូវីដ-១៩។

**អន្តរាគមន៍ និងការផ្តល់សេវាសុខភាព**

- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល នឹងរៀបចំការផ្តល់ការបណ្តុះបណ្តាលពីការព្យាបាលដោយប្រើអុកស៊ីសែនទៅគ្រប់ខេត្តទាំងអស់ត្រឹមដំណាច់ខែធ្នូឆ្នាំ២០២១នេះ។ នៅក្នុងខេត្តនីមួយៗ បុគ្គលិកមកពីផ្នែកសង្គ្រោះបន្ទាន់ និងផ្នែកព្យាបាលអ្នកជំងឺធ្ងន់នៃមន្ទីរពេទ្យខេត្ត និងស្រុកប្រតិបត្តិ នឹងទទួលបានការបង្ហាត់បង្ហាញដោយផ្ទាល់ពីក្រុមការងារថ្នាក់ជាតិ។ គិតត្រឹមថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០២១នេះ ខេត្តចំនួន ១៧ បានទទួលការបណ្តុះបណ្តាលនេះ ហើយការបណ្តុះបណ្តាល នឹងបន្តនៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរីនៅសប្តាហ៍ក្រោយ។
- បន្តផ្តល់ការគាំទ្រក្នុងការបង្ហាត់បង្រៀន ដើម្បីពង្រឹងការគ្រប់គ្រងគ្លីនិក ការផ្តល់សេវាសុខភាពដល់អ្នកជំងឺ ចំនួនគ្រែ និងប្រសិទ្ធភាពសម្រាប់ការព្យាបាលជំងឺធ្ងន់ធ្ងរ ព្រមទាំងការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ ដោយផ្តោតជាសំខាន់លើបណ្តាខេត្តជាប់ព្រំដែន។ គិតត្រឹមថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០២១ ខេត្តចំនួន ១៦ បានទទួលការបង្ហាត់បង្រៀនរួចហើយៗ កម្មវិធីបង្ហាត់បង្ហាញនេះ ត្រូវបានផ្តល់ដល់មន្ទីរពេទ្យខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។
- អនុគណៈកម្មការបច្ចេកទេស និងព្យាបាលជំងឺកូវីដ-១៩ បន្តតាមដានករណីធ្ងន់ធ្ងរ និងចំនួនគ្រែសម្រាប់ព្យាបាលអ្នកជំងឺធ្ងន់ ដោយធ្វើការជាមួយនឹងបណ្តាញថ្នាក់ខេត្ត។
- បន្តកិច្ចប្រជុំជាទៀងទាត់រវាងថ្នាក់ជាតិ និងមន្ទីរពេទ្យខេត្តទាំងអស់ ដើម្បីទទួលបានបច្ចុប្បន្នភាពអំពីស្ថានភាពពីខេត្ត ចែករំលែកបទពិសោធន៍ក្នុងខេត្ត ស្វែងយល់ពីបញ្ហាប្រឈមនៅក្នុងការអនុវត្ត និងទទួលបានដំបូន្មានពីថ្នាក់ជាតិ។
- នៅសប្តាហ៍ក្រោយ អនុគណៈកម្មការបច្ចេកទេស និងព្យាបាលជំងឺកូវីដ-១៩ នឹងផ្តួចផ្តើមកិច្ចប្រជុំលើកទីមួយសម្រាប់បុគ្គលិកគ្លីនិកដើម្បីជ្រើសរើសករណីសិក្សាកូវីដ-១៩ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងពង្រឹងចំណេះដឹងគ្លីនិកទាក់ទងនឹងការគ្រប់គ្រងអ្នកជំងឺកូវីដ-១៩ របស់បុគ្គលិកថែទាំសុខភាពជួរមុខនៅថ្នាក់ក្រោមជាតិ។

**ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍**

- ○ អង្គការសុខភាពពិភពលោក កំពុងសហការជាមួយនឹងក្រសួងសុខាភិបាល ដើម្បីពង្រឹងការចូលរួមរបស់សហគមន៍ ការចូលរួមរបស់បុគ្គលដែលមានឥទ្ធិពលនៅលើបណ្តាញសង្គម ក្រុមស្មគ្រចិត្តជួយដោយខ្លួនឯងនៅតាមភូមិ បុគ្គលិកសុខាភិបាល និងអាជ្ញាធរមូលដ្ឋាននៅក្នុងបណ្តាខេត្តអាទិភាព។
- ○ អង្គការសុខភាពពិភពលោក កំពុងគាំទ្រការត្រួតពិនិត្យការចាក់វ៉ាក់សាំងកូវីដ-១៩នៅទូទាំងប្រទេស ហើយបន្តផ្តល់ការគាំទ្រដល់ការត្រួតពិនិត្យ និងការចូលទៅដល់ក្រុមប្រជាពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាលតាមរយៈកម្មវិធីប្រាស្រ័ទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍ដោយផ្អែកលើភស្តុតាង។
- ○ អង្គការសុខភាពពិភពលោកកំពុងសហការជាមួយនឹងក្រសួងសុខាភិបាលដើម្បីផលិតប័ណ្ណប្រកាសអេឡិចត្រូនិកប្រើនៅលើបណ្តាញសង្គម ដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងពាក្យចចាមអារ៉ាម។
- ○ អង្គការសុខភាពពិភពលោក បានចេញគោលការណ៍ណែនាំសម្រាប់ការចាក់វ៉ាក់សាំងដល់ស្ត្រីដែលបំបៅដោះកូនដោយទឹកដោះម្តាយ ស្ត្រីមានផ្ទៃពោះ និងស្ត្រីមានផ្ទៃពោះ ឬមានផែនការយកកូន និងស្ត្រីកំពុងមករដូវ ព្រមទាំងការណែនាំពីវ៉ាក់សាំង និងការដែលអាចមានកូនបាន (សូមមើលតំណរភ្ជាប់សម្រាប់វីដេអូព័ត៌មាន និងតំណរភ្ជាប់សម្រាប់ប័ណ្ណប្រកាសអេឡិចត្រូនិកប្រើនៅលើបណ្តាញសង្គម និងក្រាហ្វិកព័ត៌មាន)។ ឯកសារទាំងនេះ កំពុងត្រូវបានប្រែសម្រួលជាភាសាខ្មែរ។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ជំងឺរាតត្បាតកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាពផ្លូវចិត្តរបស់ប្រជាជន។ នៅក្នុងយុទ្ធនាការទិវាសុខភាពផ្លូវចិត្តពិភពលោក ឆ្នាំនេះ (ក្រោមប្រធានបទ ការថែទាំសុខភាពផ្លូវចិត្តសម្រាប់ទាំងអស់គ្នា៖ សូមឲ្យវាក្លាយជាការពិត) អង្គការសុខភាពពិភពលោក បានចែករំលែកនូវសម្ភារសម្រាប់ប្រាស្រ័យទាក់ទងថ្មីៗ ងាយអាន អំពីរបៀបថែរក្សាសុខភាពផ្លូវចិត្តផ្ទាល់ខ្លួនរបស់អ្នក និងផ្ដល់ការគាំទ្រដល់អ្នកផ្សេងទៀតផងដែរ សូមចុចតំណរភ្ជាប់នេះ

## ការវាយតម្លៃពីការចម្លង

ការវាយតម្លៃលើការតាមដានជំងឺដោយប្រើព័ត៌មានពីប្រភពចម្រុះនាពេលបច្ចុប្បន្ន បង្ហាញថា រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ស្ថិតនៅក្នុងដំណាក់កាលចម្លងទី២ (ការចម្លងកម្រិតសហគមន៍នៅតាមតំបន់) ហើយខេត្តចំនួន៧ផ្សេងទៀត (ខេត្តកោះកុង ខេត្តកែប ខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តពោធិសាត់ ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី) ស្ថិតនៅក្នុងដំណាក់កាលចម្លងទី១។

| បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
|---|---|---|---|---|
| | 42,501<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល៧ថ្ងៃចុងក្រោយ | 725<br>ករណីវិជ្ជមានថ្មីក្នុងពេល៧ថ្ងៃចុងក្រោយ<br>(០,៦ ភាគរយ - ៧ថ្ងៃ) | 49<br>ករណីស្លាប់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(១,៨ ភាគរយ - ៧ថ្ងៃ) | 508<br>ករណីនាំចូលក្នុងពេល២៨ថ្ងៃចុងក្រោយ |
| | 2,286,961<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 118,613<br>ករណីសរុប | 2,794<br>ករណីស្លាប់សរុប | 105<br>ករណីនាំចូលពីបរទេសក្នុងរយៈពេល៧ថ្ងៃចុងក្រោយ |

| ការផ្ដល់សេវាសុខភាពអំពីកូវីដ-១៩ | | | |
|---|---|---|---|
| | 225<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 13,782<br>ចំនួនគ្រែមន្ទីរពេទ្យរដ្ឋ | 116<br>ចំនួនមន្ទីរពេទ្យដែលមានបទពិសោធន៍គ្រប់គ្រងករណីជំងឺកូវីដ-១៩ (រួមមានមូលដ្ឋានថែទាំសុខាភិបាលចំនួន៩នៅរាជធានីភ្នំពេញ ២៧មន្ទីរពេទ្យខេត្ត និង ៨០មន្ទីរពេទ្យស្រុកប្រតិបត្តិ) |



**បដិសេធការទទួលខុសត្រូវ៖** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អេពីដេមីសាស្ត្រ

ក្រាហ្វិកទី១. ខ្សែកោងអេពីដេមីសាស្ត្រនៃករណីជំងឺកូវីដ-១៩ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ២០២១*

*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ




ក្រាហ្វិកទី២. ចំនួនករណីជំងឺស្រដៀងផ្តាសាយ (ILI) មកពីកន្លែងតាមដានជំងឺស្រដៀងផ្តាសាយ (ចំនួន ៧កន្លែង) ប្រចាំសប្តាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០*

*ការរាយការណ៍ពីកន្លែងតាមដានជំងឺស្រដៀងផ្តាសាយខ្លះមានការយឺតយ៉ាវ នៅក្នុងប៉ុន្មានសប្តាហ៍នេះ






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ក្រាហ្វិកទី៣. ចំនួនករណីជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ ប្រចាំសប្តាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៧ ដល់២០២០




# អភិក្រមយុទ្ធសាស្រ្ត

**ការឆ្លើយតបសុខភាពសាធារណៈនៅថ្នាក់ជាតិ និងរាជធានី-ខេត្ត**

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

- ○ គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ដែលមានសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្រ្តីជាប្រធាន
- ○ គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ដែលមានឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន
    - ❖ គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ថ្នាក់រាជធានី-ខេត្តដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
    - ❖ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខណ្ឌទូទាំងប្រទេស
    - ❖ គណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩
- ○ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ដឹកនាំដោយរដ្ឋមន្រ្តីក្រសួងសុខាភិបាលជាប្រធាន និងអមដោយរដ្ឋលេខាធិការ
    - ❖ អនុគណៈកម្មការវាយតម្លៃ ផែនការ និងយុទ្ធសាស្រ្តដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - ❖ អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័កដឹកនាំដោយអគ្គនាយកស្រាវជ្រាវចារកិច្ចក្រសួងការពារជាតិ
    - ❖ អនុគណៈកម្មការឆ្លើយតបបន្ទាន់ និងស្រាវជ្រាវរកបុគ្គលផ្ទុកមេរោគកូវីដ-១៩ ដឹកនាំដោយអគ្គស្នងការរងនរគបាលជាតិក្រសួងមហាផ្ទៃ
    - ❖ អនុគណៈកម្មការបច្ចេកទេស និងព្យាបាល ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - ❖ អនុគណៈកម្មការសេវាមន្ទីរពិសោធន៍ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - ❖ អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - ❖ អនុគណៈកម្មការបច្ចេកទេស និងទិន្នន័យ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
    - ❖ អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងសុខាភិបាល
    - ❖ អនុគណៈកម្មការសាងសង់ និងជួសជុល ដឹកនាំដោយអគ្គស្នងការរងនគរបាលជាតិក្រសួងមហាផ្ទៃ



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ❖ អនុគណៈកម្មការគ្រប់គ្រង និងចាត់ចែងសាកសពអ្នកជំងឺកូវីដ-១៩ ដឹកនាំដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃ
- ○ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេស៤ក្រុមសម្រាប់ដោះស្រាយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមបង្កឡើងដោយជំងឺកូវីដ-១៩

## ការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ

- ○ កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ ២០២១ សេចក្តីព្រៀងច្បាប់ស្តីអំពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានអនុម័តដោយរដ្ឋសភា។
- ○ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រឹត្យនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។
- ○ ទំរង់ Go.Data (Go.Data Platform) ត្រូវបានប្រើជាមូលដ្ឋានទិន្នន័យមួយសម្រាប់ប្រមូលព័ត៌មានអំពីអ្នកប៉ះពាល់ជាមួយករណីកូវីដ-១៩ វិជ្ជមាន និងព័ត៌មានមន្ទីរពិសោធន៍។
- ○ មូលដ្ឋានទិន្នន័យរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ត្រូវបានកែសម្រួលដើម្បីអាចបញ្ចូលសំណុំទិន្នន័យប្រភពច្រើនសម្រាប់ការធ្វើតេស្ត និងតាមដានជំងឺ។

## គន្លឹះអាទិភាពសំខាន់ៗ

- កម្មវិធីថ្នាក់ជាតិកំពុងតែអភិវឌ្ឍផែនការឆ្លើយតប និងត្រៀមបង្ការដោយផ្តោតជាសំខាន់ទៅលើជំងឺកូវីដ-១៩។
- ពង្រឹងសមត្ថភាពត្រៀមខ្លួននៅថ្នាក់មូលដ្ឋាន ក្នុងករណីមានការផ្ទុះរាលដាលជំងឺនៅសហគមន៍ និងគ្រោះអាសន្នផ្នែកសុខភាពសាធារណៈដទៃទៀតនាពេលអនាគត ដើម្បីកាត់បន្ថយការរាំងស្ទះដល់ដំណើរការផ្តល់សេវាសុខភាពសំខាន់ៗ។

## អភិក្រមយុទ្ធសាស្ត្រសម្រាប់បង្ការ ស្រាវជ្រាវ និងត្រួតពិនិត្យជំងឺកូវីដ-១៩

- ○ *យុទ្ធសាស្ត្រសម្រាប់ការធ្វើតេស្ត និងប្រព័ន្ធស្វែងរកអ្នកប៉ះពាល់មានរួចរាល់*

យុទ្ធសាស្ត្រធ្វើតេស្តទូលំទូលាយមួយ កំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេស ដែលរួមមានការធ្វើតេស្តករណីសង្ស័យទាំងអស់ដែលចូលក្នុងនិយមន័យករណីសង្ស័យមានជំងឺកូវីដ-១៩ និងការឃ្លាំមើលយ៉ាងសកម្មចំពោះករណីជំងឺរលាកសាច់សួត (pneumonia) នៅតាមមន្ទីរពេទ្យ ក៏ដូចជាការធ្វើតេស្តនៅច្រកចេញ-ចូល (points of entry) នាថ្ងៃទី១ និងថ្ងៃទី៦ ឬថ្ងៃទី១៣ អាស្រ័យស្ថានភាពថាបានចាក់វ៉ាក់សាំងហើយឬនៅ និងការធ្វើតេស្តវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) ដើម្បីកំណត់រកមេរោគកូវីដ-១៩។ ការធ្វើតេស្តផ្តោតទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ (high-risk populations) កំពុងត្រូវបានអនុវត្តនៅពេលចាំបាច់។

- ○ *ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សគមន៍*

យុទ្ធសាស្ត្រសម្រាប់ស្រាវជ្រាវរកជំងឺដោយមានការចូលរួមរបស់សហគមន៍ ត្រូវបានបង្កើតឡើង និងដាក់សាកល្បងដើម្បីស្វែករកករណីជំងឺកូវីដ-១៩ នៅកម្រិតមណ្ឌលសុខភាព និងនៅក្នុងសហគមន៍។ ក្រសួងមហាផ្ទៃ កំពុងជម្រុញការត្រួតពិនិត្យការធ្វើចត្តាឡីស័កតាមរយៈការតាមដាន និងពិន័យសម្រាប់បុគ្គលដែលបំពានគោលការណ៍ណែនាំ។

- ○ *អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (មាននៅក្នុងតារាងនៅចុងបញ្ចប់នៃរបាយការណ៍នេះ)*



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

## កត្តាដែលបានរួមចំណែកដល់ការឆ្លើយតបបានល្អ

- **ភាពជាអ្នកដឹកនាំខ្លាំង និងការសម្របសម្រួលបានល្អ**
  - ការឆ្លើយតបរបស់រដ្ឋាភិបាល និងសង្គមទាំងមូល ដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី ហើយវិធានការសុខភាពសាធារណៈដឹកនាំដោយរដ្ឋមន្ត្រីសុខាភិបាល។
  - ផែនការមេថ្នាក់ជាតិសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងជាមួយនឹងថវិកាចំនួន ៦២លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ឆ្នាំទី១។
  - កាលពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រី បានដាក់ចេញនូវយុទ្ធសាស្ត្រស្តីអំពីការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ចំនួន៦ចំណុចដោយផ្តោតទៅលើការការពារមិនឲ្យមានការនាំចូលវីរុសកូវីដ-១៩បំប្លែងថ្មី ការកាត់បន្ថយភូមិសាស្ត្រដែលមានការរីករាលដាលនៃជំងឺកូវីដ-១៩ និងចំនួនករណីឆ្លង ការផ្តល់ការព្យាបាលប្រកបដោយប្រសិទ្ធភាព និងស្តង់ដារ ការពង្រឹងការស្វែងរក និងគ្រប់គ្រងអ្នកដែលប៉ះពាល់អ្នកជំងឺ ការចាត់ចែងសាកសព និងវ៉ាក់សាំងកូវីដ-១៩។
- **ការវិនិយោគកន្លងមកបានពង្រឹងដំណើរការប្រព័ន្ធសុខភាពសុខភាពសាធារណៈ**
  - ការតាមដានជំងឺកូវីដ-១៩ ដោយបានពីព័ត៌មានពហុប្រភព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ ដោយប្រើប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៥) និងប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI)។
  - ក្រុមឆ្លើយតបបន្ទាន់ជិត ៣.០០០នាក់ នៅទូទាំងប្រទេស បានស្រាវជ្រាវរកករណី និងតាមរកអ្នកប៉ះពាល់ជាមួយនឹងករណីវិជ្ជមានវីរុសកូវីដ-១៩។
- **ការទំនាក់ទំនង និងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍**
  - សារទាន់ពេលវេលា ត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម និងតាមរយៈសេចក្តីជូនព័ត៌មានទៀងទាត់ និងសន្និសីទសារព័ត៌មាន។
  - អភិក្រមដែលផ្អែកលើហានិភ័យសម្រាប់ការរៀបចំបង្កើតសម្ភារប្រាស្រ័យទាក់ទងជនគោលដៅ មានហានិភ័យខ្ពស់ ដូចជាជនទេសន្តប្រវេសន៍(ពលករចំណាកស្រុក) កម្មកររោងចក្រ ទីផ្សារលក់ដូរ ពន្ធនាគារ ភោជនីយដ្ឋាន-បារជាដើម ត្រូវបានបង្កើតឡើង។
  - យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានអនុវត្តដើម្បីគ្របដណ្តប់គ្រប់ផ្នែកនៃការតាមដានជំងឺ និងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ជាពិសេសត្រៀមសម្រាប់ពេលមានការឆ្លងទៅសហគមន៍ណាមួយ។
  - មានកិច្ចសម្របសម្រួល និងសហប្រតិបត្តការណ៍ជិតស្និទ ក្នុងចំណោមភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងការអនុវត្តសកម្មភាពការងារលើកកំពស់ការចូលរួមរបស់សហគមន៍ និងការប្រាស្រ័យទាក់ទងអំពីហានិភ័យ ការតាមដាន កែសម្រួល និងពង្រឹងការអនុវត្ត។
- **សាមគ្គីភាព និងសហប្រតិបត្តិការអន្តរជាតិ**
  - ការឆ្លើយតបដោយប្រព័ន្ធសុខាភិបាលមួយដែលមានតម្លាភាព និងបើកចំហ។
  - កិច្ចសហការបច្ចេកទេស និងប្រតិបិត្តិការជិតស្និទ្ធរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
  - ការចូលរួមនៃមន្ត្រីជាន់ខ្ពស់នៅកិច្ចប្រជុំអន្តរជាតិនានា រួមទាំងការសម្របសម្រួលជាទៀងទាត់ក្នុងចំណោមបុគ្គលិកទទួលបន្ទុកផ្នែកច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# ការចាក់វ៉ាក់សាំងកូវីដ-១៩

គិតត្រឹមថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២១៖

- **បច្ចុប្បន្នភាព**
  - កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ កម្ពុជាបានចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេសសម្រាប់កុមារអាយុ ៥ឆ្នាំដោយប្រើវ៉ាក់សាមងស៊ីណូវ៉ាក់។
  - យុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេសសម្រាប់កុមារអាយុ ៦ឆ្នាំឡើង ត្រូវបានប្រកាសបិទបញ្ចប់ជាផ្លូវការក្រោមអធិតបតីភាពរបស់សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែការចាក់វ៉ាក់សាំងជូនដល់កុមារ និងប្រជាពលរដ្ឋអាយុចាប់ពី ៦ឆ្នាំឡើង ដែលនៅសេសសល់ក្រោយការប្រកាសបិទយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ជុំទីមួយ នៅតែបន្តនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាពដែលបានកំណត់។
- **ចំនួនដូសវ៉ាក់សាំងដែលបានទទួលមកទល់នឹងបច្ចុប្បន្ន**

  រាជរដ្ឋាភិបាលកម្ពុជា ទទួលបានវ៉ាក់សាំងកូវីដ-១៩ សរុបទាំងអស់ចំនួន ៣៧.៧៣១.៤៤០ ដូស ដែលក្នុងនោះ៖
  - ចំនួន ២៨.៥០០.០០០ដូស ឬស្មើនឹង ៧៥ ភាគរយតាមរយៈការបញ្ជាទិញពីសាធារណរដ្ឋប្រជាមានិត្យចិន
  - ចំនួន ៦.៧១៥.០៤០ដូស ឬស្មើនឹង ១៨ ភាគរយតាមរយៈជំនួយពីសាធារណរដ្ឋប្រជាមានិតចិន និងចក្រភពអង់គ្លេស (៦.៣០០.០០០ដូសជាជំនួយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិត្យចិន និងចំនួន ៤១៥.០៤០ដូសជាជំនួយរបស់ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស)។
  - ចំនួន ២.៥១៦.៤០០ដូស ឬស្មើនឹង ៧ ភាគរយតាមរយៈជំនួយពីមជ្ឈមណ្ឌលកូវ៉ាក់ (ដែលក្នុងនោះរួមមានជំនួយពីរដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលសហរដ្ឋអាមេរិក)។
  - វ៉ាក់សាំងកូវីដ-១៩ ចំនួន ៦.៤០៦.២៨៤ ដូសនៅសល់ក្នុងស្តុកនៅឃ្លាំងឱសថកណ្តាលរបស់ក្រសួងសុខាភិបាល។
- **លទ្ធផលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩**

  ***១. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់បុគ្គលិកសុខាភិបាល និងមនុស្សចាស់អាយុចាប់ពី ៦០ឆ្នាំឡើង***
  - បុគ្គលិកសុខាភិបាលចំនួន ៤២.៥៦២នាក់ (៩៧.៦ ភាគរយ) បានទទួលវ៉ាក់សាំងកូវីដ-១៩ដូសទីមួយ។
  - បុគ្គលិកសុខាភិបាលចំនួន ៤២.៥៥៦នាក់ (៩៧.៦ ភាគរយ) បានទទួលវ៉ាក់សាំងកូវីដ-១៩ដូសទីពីរ។
  - មនុស្សចាស់ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅចំនួន ១.៣៧៤.៦២៦នាក់ (៩៩.៧ ភាគរយ) បានទទួលវ៉ាក់សាំងកូវីដ-១៩ដូសទី.មួយ។
  - មនុស្សចាស់ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅចំនួន ១.៣២១.២៥៨នាក់ (៩៥.៨ ភាគរយ) បានទទួលវ៉ាក់សាំងកូវីដ-១៩ដូសទីពីរ។

  ***២. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់បុគ្គលមានអាយុចាប់ពី ១៨ឆ្នាំឡើង***
  - បុគ្គលចំនួន ១០.០០៥.១៩៩នាក់ (១០០ ភាគរយនៃប្រជាជនគោលដៅអាយុចាប់ពី១៨ឆ្នាំឡើងទៅ) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទីមួយ។
  - បុគ្គលចំនួន ៩.៦៤២.០៦៩ (៩៦.៤ ភាគរយនៃប្រជាជនគោលដៅអាយុចាប់ពី១៨ឆ្នាំឡើងទៅ) បានទទួលវ៉ាក់សាំងកូវីដ-១៩ដូស ទីពីរ។
  - ចំនួនស្ត្រីដែលបានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទីមួយ និងដូសទីពីរគឺស្មើនឹង ៥០ ភាគរយនៃចំនួនដូសដែលបានចាក់សរុប។

  ***៣. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់កុមារ និងយុវជនអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម១៨ឆ្នាំ***
  - កុមារ និងយុវជនអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ សរុបចំនួន ១.៧៨៩.៥៨៧ (៩៧.៩ ភាគរយ) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទីមួយ ហើយកុមារ និងយុវជនអាយុចាប់ពី ១២ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ សរុបចំនួន ១.៦៩៨.២៤៧ (៩២.៩ ភាគរយ) បានចាក់វ៉ាក់សាំងកូវីដ-១៩ដូសទីពីរ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- សមាមាត្រនៃកុមារី និងយុវនារីដែលបានទទួលដូសទីមួយ និងដូសទីពីរគឺ ៤៩ភាគរយ នៃចំនួនដូសសរុបដែលបានចាក់។

*៤. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់កុមារ និងយុវជនអាយុចាប់ពី ៦ ឆ្នាំ ដល់ក្រោម១២ឆ្នាំ*

- កុមារ និងយុវជនអាយុចាប់ពី ៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ សរុបចំនួន ១.៩២៥.០២៩ (១០១.៥ ភាគរយនៃចំនួនកុមារគោលដៅអាយុពី៦ឆ្នាំដល់ក្រោម១២ឆ្នាំសរុប) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទីមួយ ។
- កុមារ និងយុវជនអាយុចាប់ពី ៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ សរុបចំនួន ១.៧៤០.៧៥៧ (៩១.៧ ភាគរយនៃចំនួនកុមារគោលដៅអាយុពី៦ឆ្នាំដល់ក្រោម១២ឆ្នាំសរុប) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទីពីរ ។
- សមាមាត្រនៃកុមារីដែលបានទទួលដូសទីមួយ និងដូសទីពីរ មានចំនួន ៤៩ភាគរយ នៃចំនួនដូសសរុបដែលបានចាក់។

*៥. លទ្ធផលចាក់វ៉ាក់សាំងសម្រាប់កុមារអាយុ ៥ ឆ្នាំ*

- កុមារ អាយុ ៥ឆ្នាំ សរុបចំនួន ២៦.៨១០នាក់ (៨.៨ ភាគរយនៃចំនួនកុមារគោលដៅអាយុ៥ឆ្នាំសរុប) បានទទួលវ៉ាក់សាំងកូវីដ-១៩ ដូសទីមួយ។

*៦. លទ្ធផលចាក់វ៉ាក់សាំងដូសជម្រុញ*

- មានអាយុចាប់ពី១៨ឆ្នាំឡើង ដែលក្នុងនោះរួមមានបុគ្គលិកសុខាភិបាល មន្ត្រីរាជការជួរមុខមនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើង និងអ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយសរុបចំនួន បុគ្គលចំនួន ១.៨៨៥,៩១១ (១៨.៩ភាគរយ) បានចាក់វ៉ាក់សាំងដូសជម្រុញ។
- សមាមាត្រនៃស្ត្រីដែលបានទទួលដូសជម្រុញ មានចំនួន ៤៦ ភាគរយនៃចំនួនដូសសរុបដែលបានចាក់។

- **សុវត្ថិភាពវ៉ាក់សាំងកូវីដ-១៩**

ហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ចំនួន ២០៦ ករណី ត្រូវបានរាយការណ៍ពីខេត្តចំនួន ២៥ ហើយអត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស គឺមាន០,៧៣ ភាគរយ។

- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងស៊ីណូវ៉ាក់ (៩៥ករណី) គឺមាន០,៥៣ ភាគរយ។
- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងស៊ីណូហ្វាម (៧៨ករណី) គឺមាន១,១០ ភាគរយ។
- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំងអាស្ត្រាហ្សេណេកាកូវីសែល (២៩ករណី) គឺមាន១,៦៤ ភាគរយ។
- អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស សម្រាប់វ៉ាក់សាំង Johnson & Johnson (៣ករណី) គឺមាន០,៣៨ ភាគរយ។

- បានចុះទីវាល និងតាមដានការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទីពីរឱ្យកុមារអាយុពី ៦ដល់ ១១ឆ្នាំ និងកុមារដែលខកខាន មិនបានចាក់វ៉ាក់សាំងដូសទីពីរនៅតាមមណ្ឌលចាក់វ៉ាក់សាំងចំនួន២ នៅក្នុងរាជធានីភ្នំពេញ និងមួយមណ្ឌលនៅខេត្តកណ្ដាល។
- បន្តការវិភាគលើការចាក់វ៉ាក់សាំង និងទិន្នន័យពីហេតុការណ៍កើតមានក្រោយចាក់វ៉ាក់សាំងតាមខេត្ត និងប្រជាពលរដ្ឋតាម ៣ក្រុមអាយុចំនួន (មនុស្សពេញវ័យ យុវជន និងកុមារ) រៀបចំរបាយការណ៍ និងចែករំលែកទៅកាន់ភាគីពាក់ព័ន្ធ និងក្នុងចំណោមបុគ្គលិកអង្គការសុខភាពពិភពលោក និងដៃគូ។
- បានផ្តល់យោបល់ជាយុទ្ធសាស្ត្រផ្នែកបច្ចេកទេសនៃកម្មវិធីជាតិចាក់ថ្នាំបង្ការនៃក្រសួងសុខាភិបាល និងតាមដានការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់កុមារអាយុពី ៦ឡើងទៅ។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (Non-Pharmaceutical Interventions)

- កាលពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០២១ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកប្រទេសឡើងវិញនៅលើគ្រប់វិស័យចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០២១តទៅ។
- កាលថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង (City Bus) រាជធានីភ្នំពេញ បានជូនដំណឹងស្តីពីការដាក់ឱ្យដំណើរការឡើងវិញនូវសេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង និងកាណូត ចាប់ពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១តទៅ ដោយតម្រូវឱ្យអ្នកដំណើរទាំងអស់គោរពតាមវិធានសុខាភិបាល ដោយត្រូវបង្ហាញប័ណ្ណចាក់វ៉ាក់សាំងសម្រាប់មនុស្សពេញវ័យ ពាក់ម៉ាស់ លាងដៃនិងអាកុល វាស់កម្តៅ ស្កេន QR Code និងអង្គុយតាមកៅអីដែលបានរៀបចំ។
- កាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០២១ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអនុញ្ញាតឱ្យបើកដំណើរសារមន្ទីរ រោងភាពយន្ត និងរោងសម្តែងសិល្បៈឡើងវិញ។
- កាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០២១ រដ្ឋបាលរាជធានីភ្នំពេញ បានសម្រេចបន្តផ្អាកជាបណ្តោះអាសន្នចំពោះសកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ដូចជាខារ៉ាអូខេ រង្គសាល និងឌីស្កូតែក និងការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជនដែលមានមនុស្សចូលរួមលើសពី៥០នាក់ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។
- កាលពីថ្ងៃទី ២៥ និង ២៦ ខែតុលា ឆ្នាំ២០២១ ក្រសួងសុខាភិបាល ចេញសេចក្តីជូនដំណឹងស្តីពីការលើកលែងការធ្វើចត្តាឡីស័កចំពោះក្រុមគ្រូពេទ្យ និងក្រុមផ្តល់សេវាជួរមុខ និងការលើកលែងកាតព្វកិច្ចធ្វើចត្តាឡីស័កចំពោះអ្នកជំងឺកូវីដ-១៩ដែលបានបញ្ចប់ការព្យាបាលនៅតាមមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ និងអ្នកជំងឺកូវីដ-១៩សម្រាកថែទាំ និងព្យាបាលនៅតាមផ្ទះ។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២ . ការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ និងថ្ងៃដែលលើកបម្រាមវិញ (NPI implementation and lifting dates)**

| អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (NPI) | ស្ថានភាពត្រួតពិនិត្យ (Monitoring status) | | | | | |
|---|---|---|---|---|---|---|
| | | | ការអនុវត្ត (Implementation) | | ការលើកបម្រាមវិញដោយផ្នែក (Partial lift) | លើកបម្រាមវិញ (Lifted) |
| | ថ្ងៃទី១នៃការអនុវត្ត (Date first implemented) | ថ្ងៃកែប្រែចុងក្រោយ (Date last modified) | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ) Geographical (national or sub-national) | ណែនាំឲ្យ ឬតម្រូវឲ្យ (Recommended or Required) | លើកសម្រាប់វិស័យ/ផ្នែកខ្លះ (Lifted for some area) | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ (Lifted for all areas) |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ (None) | ១៦ សីហា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | | មិនទាន់លើកទេ (No) |
| បិទសាលារៀន (School Closure) | ១៦ មិនា ឆ្នាំ២០២០ | ១ វិច្ឆិកា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ (Recommended) | បានលើកហើយ (Yes) | លើកបម្រាមហើយ (Yes) |
| បិទកន្លែងធ្វើការ (Workplace Closure) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| ការជួបជុំមនុស្សម្នាច្រើន (Mass Gatherings) | ៣ មេសា ឆ្នាំ២០២០ | ១៩ មិថុនា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| នៅផ្ទះ (Stay at Home) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស (Restrictions on Internal Movement (within country)) | ៩ មេសា ឆ្នាំ២០២០ | ២៩ កក្កដា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ (Recommended) | បានលើកហើយ (Yes) | លើកហើយ (Yes) |
| ការរឹតបន្តឹងលើការធ្វើដណើរអន្តរជាតិ (Restrictions on International Travel) | ២៧ មិនា ឆ្នាំ២០២០ | ២៣ តុលា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | លើកហើយ (Yes) |
| ផ្សេងៗទៀត សូមបញ្ជាក់ដោយពណ៌នា (Others; specify in narrative) | មិនមានទេ (None) | មិនមានទេ (None) | - | - | - | - |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។